# គោលនយោបាយប្រឆាំងការរើសអើងជាតិសាសន៍

សូមគោរពឪពុកម្ដាយ និងអ្នកថែទាំ

ក្រសួងអប់រំបដិសេធគ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ ហើយប្ដេជ្ញាលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ នៅសាលារៀនរដ្ឋនៅរដ្ឋ NSW។ Anti-Racism Policy (គោលនយោបាយប្រឆាំងការរើសអើងជាតិសាសន៍) របស់ក្រសួង មានគោលបំណងធានាថាគ្មានសិស្ស បុគ្គលិក ឪពុកម្ដាយ អ្នកថែទាំ ឬសមាជិកសហគមន៍ ជួបប្រទះការរើសអើងជាតិសាសន៍នៅក្នុងបរិយាកាសសាលាឡើយ។

គោលការណ៍ស្នើឱ្យសមាជិកទាំងអស់នៃសហគមន៍សាលារៀន ជួយក្នុងការប្រឆាំងនឹងការរើសអើងជាតិសាសន៍ ដោយការបង្ហាញនូវការគោរពចំពោះសាវតារវប្បធម៌ ភាសា និងសាសនារបស់អ្នកដទៃ និងដោយការប្រកាន់អាកប្បកិរិយាក្នុងវិធីដែលលើកកម្ពស់ការទទួលយក និងភាពចុះសម្រុងគ្នានៅក្នុងបរិយាកាសសាលា។

សាលារៀននីមួយៗមានមន្ត្រីទំនាក់ទំនងប្រឆាំងការរើសអើងជាតិសាសន៍ (Anti-Racism Contact Officer (ARCO)) ដែលបានបណ្ដុះបណ្ដាលដើម្បីជួយប្រឆាំងនឹងការរើសអើងជាតិសាសន៍ និងគាំទ្រសហគមន៍សាលារៀន នៅពេលធ្វើបណ្ដឹងតវ៉ា អំពីការរើសអើងជាតិសាសន៍នៅសាលារៀន។ សម្រាប់ព័ត៌មានបន្ថែមអំពីគោលនយោបាយ និងតួនាទីរបស់ ARCO សូមមើល Anti-Racism Policy - Information for parents and carers (គោលនយោបាយប្រឆាំងការរើសអើងជាតិសាសន៍ - ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ)។

សូមអរគុណអ្នកចំពោះការជួយពួកយើង ដើម្បីរក្សាបរិយាកាសវិជ្ជមាននៅសាលារៀន ដែលគ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ត្រូវបានបដិសេធ។ សូមទាក់ទងមកខ្ញុំ ប្រសិនបើអ្នក ឬកូនរបស់អ្នកជួបប្រទះនឹងទម្រង់នៃការរើសអើងជាតិសាសន៍ណាមួយ ឃើញហេតុការណ៍ដែលនរណាម្នាក់កំពុងជួបប្រទះការរើសអើងជាតិសាសន៍នៅសាលារៀនរបស់យើង ឬប្រសិនបើអ្នកចង់ទទួលបានព័ត៌មានបន្ថែម ឬការគាំទ្រ។

ដោយសេចក្ដីរាប់អាន

នាយកសាលា

## ជំនួយអ្នកបកប្រែផ្ទាល់មាត់

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ហើយអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការទាក់ទងមកសាលារៀន ឬនាយកសាលា សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទរបស់សាលារៀន ពេលនោះការីទូរសព្ទនឹងទូរសព្ទទៅសាលារៀន ហើយរៀបចំ អ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកក្នុងការសន្ទនារបស់អ្នក។

អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មបកប្រែផ្ទាល់មាត់ទេ។